អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# នួន ជា



**គោត្តនាម** ៖ នួន **នាម** ៖ ជា

**សំណុំរឿងលេខ** ៖ ០០២/១៩-០៩-២០០៧/អវតក-អជសដ

**សវនាការសាធារណៈលើកក្រោយ** ៖ ២៧ មិថុនា ២០១១

**កាលបរិច្ឆេទនិងទីកន្លែងកំណើត** ៖ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩២៦ នៅភូមិវត្តគរ ខេត្តបាត់ដំបង

**ចាប់ខ្លួន** ៖ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧

**មេធាវីការពារក្តី**៖ លោក សុន អរុណ (មេធាវីជាតិ) លោក មីឃៀល ផេស្តមេន (Michiel Pestman) (មេធាវីអន្តរជាតិ ជនជាតិហូឡង់) និង លោក វីកទ័រ គូប៉េ (Victor Koppe) (មេធាវីអន្តរជាតិ ជនជាតិហូឡង់)

| | |
|---|---|
| **ស្ថានភាពបច្ចុប្បន្ន** | ត្រូវចោទប្រកាន់និងបញ្ជូនទៅជំនុំជម្រះពីបទ **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា** ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងមានចែងនិងផ្តន្ទាទោស តាមមាត្រា ៣(ថ្មី) មាត្រា៤, ៥, ៦, ២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។<br><br>សវនាការបឋមនឹងចាប់ផ្តើមនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១។ |
| **តួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ** | អនុលេខាបក្សនៃបក្សកុម្មុយនីស្តកម្ពុជា សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ប្រធានសភាប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យ។ យោងតាមដីកាដំណោះស្រាយ នួន ជា ក៏ត្រូវបានចោទប្រកាន់ថា |

ជាសមាជិកគណៈកម្មាធិការឃោសនានៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែ នួន ជា បានបដិសេធតួនាទីនេះ។

**បទចោទប្រកាន់សំខាន់ៗ**

នួន ជា ត្រូវបានចោទប្រកាន់ថា មានការទទួលខុសត្រូវតាមរយៈការធ្វើសកម្មភាព ឬបរាជ័យក្នុងការទប់ស្កាត់(រួមបញ្ចូលទាំងការប្រព្រឹត្តតាមរយៈឧក្រិដ្ឋកម្មរួម) បញ្ជា ញុះញង់ រៀបចំផែនការ ដឹកនាំ ឬសមគំនិត ដោយការជួយឬជំរុញ ឬបង្កលក្ខណៈងាយស្រួលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំ ចំពោះឧក្រិដ្ឋកម្មដូចខាងក្រោម ដែលត្រូវបានប្រព្រឹត្តនៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩៖

**ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** ៖ មនុស្សឃាត ការសម្លាប់ផ្តាច់ពូជ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត។

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍** ៖ ការសម្លាប់រង្គាលក្រុមជនជាតិវៀតណាមនិងចាម។

**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩** ៖ មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្មឬការប្រព្រឹត្តអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរឬឲ្យមានការឈឺចាប់ដល់រូបរាងកាយឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ ការបង្ខាំងនិងការនិរទេសជនស៊ីវិលដោយខុសច្បាប់។

**អំពើមនុស្សឃាត** ៖ ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។

នួន ជា បានបដិសេធរាល់បទចោទប្រកាន់ទាំងអស់មកលើគាត់។

**ប្រវត្តិរូបផ្ទាល់ខ្លួន**

នួន ជា (ឈ្មោះកំណើត ឡុង ប៊ុនរួត) បានសិក្សាច្បាប់នៅសាកលវិទ្យាល័យធម្មសាត នៅទីក្រុងបាងកក ហើយនៅទីនោះ គាត់បានចូលរួមជាមួយបក្សកុម្មុយនីស្តថៃ។ នៅឆ្នាំ១៩៦០ គាត់ត្រូវបានតែងតាំងជាអនុលេខាបក្សនៃបក្សកុម្មុយនីស្តកម្ពុជា និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ហើយគាត់ស្ថិតនៅក្នុង

តំណែងទាំងពីរនេះពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់រស់នៅជាមួយខ្មែរក្រហមរហូតដល់មានកិច្ចព្រមព្រៀងគ្នាមួយជាមួយរដ្ឋាភិបាលកម្ពុជានៅខែធ្នូ ឆ្នាំ១៩៩៨ ដែលអនុញ្ញាតឲ្យគាត់មករស់នៅក្បែរព្រំដែនថៃ។

| | | |
|---|---|---|
| **ប្រវត្តិនៃសំណុំរឿង** | ១៩ កញ្ញា ២០០៧ | នួន ជា ត្រូវបានចាប់ខ្លួន និងឃុំខ្លួនជាបណ្ដោះអាសន្ននៅ អ.វ.ត.ក សម្រាប់រយៈពេលមួយឆ្នាំ តាមដីកាឃុំខ្លួនបណ្ដោះអាសន្នដែលចេញដោយសហចៅក្រមស៊ើបអង្កេតក្នុងថ្ងៃដដែល |
| | ១២ វិច្ឆិកា ២០០៧ | នួន ជា ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ប្រឆាំងនឹងដីកាឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន |
| | ២០ មីនា ២០០៨ | អង្គបុរេជំនុំជម្រះបដិសេធបណ្ដឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន |
| | ១៦ កញ្ញា ២០០៨ | សហចៅក្រមស៊ើបអង្កេតចេញដីកាសម្រេចពន្យារពេលឃុំខ្លួន នួន ជា ជាបណ្ដោះអាសន្ន សម្រាប់រយៈពេលមួយឆ្នាំទៀត |
| | ១៦ តុលា ២០០៨ | នួន ជា ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុះជម្រះ ប្រឆាំងនឹងដីកាពន្យារពេលឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន |
| | ៤ ឧសភា ២០០៩ | អង្គបុរេជំនុំជម្រះបដិសេធបណ្ដឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាពន្យារពេលឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន |
| | ១៥ កញ្ញា ២០០៩ | សហចៅក្រមស៊ើបអង្កេតចេញដីកាសម្រេចពន្យារពេលឃុំខ្លួន នួន ជា ជាបណ្ដោះអាសន្នសម្រាប់រយៈពេលមួយឆ្នាំទៀត |
| | ១៤ មករា ២០១០ | សហចៅក្រមស៊ើបអង្កេតចេញសេចក្ដីជូនដំណឹងទៅ នួន ជា អំពីការពិចារណារបស់សហចៅក្រមស៊ើបអង្កេតក្នុងការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការស៊ើបអង្កេត |
| | ១៩ កក្កដា ២០១០ | សហចៅក្រមស៊ើបអង្កេតបញ្ជូនឯកសារសំណុំរឿងទៅសហព្រះរាជអាជ្ញា ដើម្បីឲ្យសហព្រះរាជអាជ្ញារៀបចំសេចក្ដីសន្និដ្ឋានស្ថាពរ |

| | | |
|---|---|---|
| | ១៦ សីហា ២០១០ | សហព្រះរាជអាជ្ញាចេញសេចក្តីសន្និដ្ឋានស្ថាពរ និងលើកសំណើទៅសហចៅក្រមស៊ើបអង្កេត ឲ្យចោទប្រកាន់ នួន ជា និងបញ្ជូនសំណុំរឿងទៅជំនុំជម្រះ |
| | ១៥ កញ្ញា ២០១០ | សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយ ដោយចោទប្រកាន់ នួន ជា និងបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។ នួន ជា ត្រូវបានបន្តឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងជាបណ្តោះអាសន្នរហូតដល់ពេលដែលត្រូវនាំយកទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង |
| | ១៨ តុលា ២០១០ | នួន ជា ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ជំទាស់ទៅនឹងយុត្តាធិការនៃដីកាដំណោះស្រាយ |
| | ១៣ មករា ២០១១ | អង្គបុរេជំនុំជម្រះបានបញ្ជាក់និងធ្វើវិសោធនកម្មដោយផ្អែកទៅលើបទចោទប្រកាន់ប្រឆាំងនឹង នួន ជា ដែលមានចែងនៅក្នុងដីកាដំណោះស្រាយនិងសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។ នួន ជា ត្រូវបានបន្តឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងជាបណ្តោះអាសន្នរហូតដល់ពេលដែលត្រូវនាំយកទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ |
| | ១៨ មករា ២០១១ | នួន ជា ដាក់ពាក្យបណ្តឹងទៅអង្គជំនុំជម្រះសាលាដំបូងទាមទារឲ្យដោះលែងរូបគាត់ជាបន្ទាន់ |
| | ១៦ កុម្ភៈ ២០១១ | អង្គជំនុំជម្រះសាលាដំបូងបដិសេធពាក្យបណ្តឹងទាមទារដោះលែងឲ្យនៅក្រៅឃុំរបស់ នួន ជា |

*ដីកានិងសេចក្តីសម្រេចទាំងនេះ និងផ្សេងៗទៀត សូមមើល:

http://www.eccc.gov.kh/document/court

| អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | |
|---|---|
| ព័ត៌មានទាក់ទងនឹងសំណុំរឿងនេះរៀបចំដោយផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក ដើម្បីជាជំនួយដល់សាធារណជន ឲ្យមានការយល់ដឹងអំពីសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក។ ឯកសារនេះពុំមែនជាឯកសារផ្លូវការផ្នែកច្បាប់ណាមួយនោះទេ បើទោះបីជាមានការខិតខំប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីធានាដល់តម្លាភាពព័ត៌មានក៏ដោយ។ | **អាសយដ្ឋាន:** ផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ប្រអប់សំបុត្រលេខ៧១ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា<br>ទូរស័ព្ទ: (៨៥៥)២៣ ២១៩ ៨១៤<br>ទូរសារ: (៨៥៥) ២៣ ២១៩ ៨៤១<br>សារអេឡិកត្រូនិក: info@eccc.gov.kh |